# Progress Report of the 2nd CDCF's JMI and Priority Activities for Aid Effectiveness and Proposed New JMI for the 3rd CDCF Meeting

## 1. Introduction

The Technical Working Group on Forestry and Environment (TWG-F&E) was established in 2004 by the Royal Government of Cambodia. Its Secretariat was structured later and fully functional in July 2006.

TWG-F&E is a mechanism and playing as forum for aid and support coordination among forestry stakeholders at technical level for Government-Donor Coordination in the forestry sectors.

The TWG-F&E Chairman is H.E TY SOKHUN, the Delegate of the Royal Government of Cambodia in charge as the Head of the Forestry Administration and the Lead Facilitator is a representative of the Development Partner, Danida.

The Secretariat is currently fully supported by Danida through the Multi-Donor Livelihoods Facility (Danida-Dfid-NZAID).

There are 21 Members of the TWG-F&E include representatives and from:

- **RGC institutions:** Forestry Administration (FA); Ministry of Environment (MoE); Council for Development of Cambodia (CDC); Ministry of Economy and Finance (MEF); Ministry of Industry, Mines and Energy (MIME); Ministry of Land Management, Urban Planning and Construction (MLMUPC); Ministry of National Defense (MND); Ministry of Commerce (MoC).
- **Development Partners:** Danida/Dfid; JICA; EC/EU; FAO; USAID; UNDP, AFD; WB
- **NGOs:** WCS; RECOFTC, PACT, NGO Forum.
- **Private sector:** Cambodia Timber Industry Association (CTIA)

## 2. Progress of TWG-F&E's JMI of the 2nd CDCF (4-5 Dec 2008)

The objective of the JMIs is target number 9: With the aim of stopping the loss of Cambodia's forest resources responding to CMDG and Rectangular Strategy to support Sustainable Forest Management for rural poverty reduction and climate change mitigation. The legal frameworks established by the Forestry Law, Protected Area Law, Land Law, Mining Law, and in particular the Sub-Decree on Economic Land Concessions must be fully implemented at all levels of Government agencies, whilst prioritizing the finalization of National Forest Program and Community Forestry development. There are four main indicators:

2.1 Implement all provisions of the applicable laws and regulations, including establishing and making public the log book of Economic Land Concessions, Mining Concessions and other concession forms under the jurisdiction of MAFF, MoE, MIME.

- MAFF granted ELCs with total land area of 992,800 ha to 87 companies with registration in logbook. 72 ELC information were publicized at the website www.elc.maff.gov.kh. and others will be updated soon.
- MIME granted 100 exploration licenses to 67 companies and only few companies are conducting feasibility studies.

- MoE granted land for investment development of 348,656 ha to the investment companies.

Land concessions are a challenge to the maintaining 60% of forest cover of country land as set in NSDP and CMDG.

2.2 At least 1,000 Km of forestland boundary and two more protected areas demarcated both on the map and ground.

- In 2009 the Forestry Administration and NGOs demarcated forest estate boundary of 228.585 Km.
- MoE demarcated boundary of 2 Protected Areas (Wildlife Sanctuary Samkos and Kolen Promtep) and mapping.

The challenge is lack of financial resources and limited collaboration from relevant local authorities.

2.3 At least 100 Community Forestry Sites (CFs) and 10 Community Protected Areas (CPAs) officially approved.

- Four Community Forestry sites were approved by MAFF.
- MoE: 11 Community Protected Areas were established and approved.

The challenge, MAFF is slowly review and approve on the proposed CF sites. Proposed 175 Community Forestry sites are pending at MAFF for approval.

2.4 Finalize and approve the National Forest Program (NFP) in September 2009; and start implementation it by the end of 2009.

The NFP development was completed in October and submitted to MAFF for approval and submit to RGC for approval. While pending approval from MAFF, development of work plan 2010 and a 5-year work plan is started.

## 3. Priority Activities for Aid Effectiveness

Following the Accra Agenda for Action and in order to enhance aid effectiveness the Forestry Administration has identified two main activities and approved by the 14$^{th}$ GDCC meeting in April 2009.

### 3.1. Build Up Capacity for Planning, Implementing, Monitoring, and Evaluation and strengthening M&E system within FA.

Development of Work Plan 2010 aligns with the NFP is an exercise for building capacity in planning. The Forestry Administration set up an M&E Office and a proposal for strengthening M&E system was submitted to Danida for support.

### 3.2. Develop and Implement National Forest Program (NFP).

NFP development was completed and pending approval from MAFF and the RGC. Development of one year work plan 2010 and a 5-year work plan is started and expected to completed in May 2010.

## 4. Recommendation

- MoE should appoint a new representative preferably high level enough in decision making, has good cooperation to joint as member of the TWG-F&E and actively participates and share information among TWG-F&E members.

- Granting Economic Land Concession in forest areas and Protected Areas should be stopped. ELC companies have to follow its master plan, especially for the investment of tree planting in order to increase forest cover as much as possible.
- MAFF should take action in time to review and approve on the proposed potential community forestry areas and the proposed National Forest Program.
- Provide more human resource and funding to FA for implementing NFP. Full cooperation from local authorities is needed.
- All Development Partners, international and local NGOs who are supporting the forestry sector must to share information with TWG-F&E.

## 5. New JMI for the 3rd CDCF

Based on the NSDP and National Forest Program the TWG-F&E would like to propose new JMI for the 3rd CDCF. They will be implemented for the period of 18 months - end of 2011.

### Immediate Outcome

Forest Cover of country land area will be maintained by increasing of quality through better management of forest resources. There are 4 main Activities:

- Reforestation of 25,000 ha degraded lands.
- 750 Km of forest estate demarcated by FA and 4 Protected Areas demarcated by MoE.
- 100 Community Forestry approved by MAFF and 7 Community Protected Areas approved by MoE.
- Cambodia REDD Readiness Road Map approved and started implementation.

Full information please see attached table.

The progress report and proposed new JMI have been discussed and approved by TWG-F&E during its 25th Meeting on the 3rd March 2010.

| Jacob K. Jepsen | H.E Ty Sokhun |
| --- | --- |
| Lead Facilitator of TWG-F&E | Chairman of TWG-F&E |

## New JMI of TWG-F&E for the 3rd CDCF

<table>
<tr><th colspan="3">Results: outcome, output and indicators</th><th colspan="2">Activities: milestone actions</th><th colspan="4">Inputs: management, coordination and resourcing</th></tr>
<tr><th>immediate outcome</th><th>output</th><th>output indicator</th><th>Activity</th><th>Associated aid effectiveness actions</th><th>Coordinating institution</th><th>Implementing institution</th><th>Timeline</th><th>Funding and other inputs</th></tr>
<tr><td>1</td><td>2</td><td>3</td><td>4</td><td>5</td><td>6</td><td>7</td><td>8</td><td>9</td></tr>
<tr><td rowspan="4">Forest cover of country land area will be maintained by increasing of quality and quantity through better management of forest resources.</td><td rowspan="4">NFP implementation in the planning and management of the forest sector improved.</td><td rowspan="4">Promotion of the NFP implementation at both national and sub-national levels, at least 75% of all funds to forest sector should be aligned to NFP framework.</td><td>Reforestation of 25,000 ha of degraded lands</td><td rowspan="2">Consolidate annual work plan to support the national and sub-national level</td><td>FA, MAFF</td><td>FA, private companies</td><td rowspan="4">18 months</td><td>RGC, private companies</td></tr>
<tr><td>750 Km of forest estate demarcated by FA, and 4 Protected Areas demarcated by MoE</td><td>FA, DPs, MAFF and local authorities</td><td>FA, NGO</td><td>RGC, DPs, NGOs</td></tr>
<tr><td>100 Community Forestry approved by MAFF and 7 Community Protected Areas approved by MoE</td><td>Approval of mapping of two million CF areas of forestland by MAFF</td><td>FA, DPs, MAFF, MoE and local authorities</td><td>FA, MAFF, MoE, NGO</td><td>RGC, DPs, NGOs</td></tr>
<tr><td>Cambodia REDD Readiness Road Map approved and started implementation</td><td>Produce legal procedures and legislations for REDD</td><td>FA, MAFF, MoE DPs, NGO</td><td>FA, MoE, DPs</td><td>RGC, DPs, NGOs</td></tr>
</table>

**របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា និង វឌ្ឍនភាពនៃការអនុវត្តសកម្មភាព អាទិភាពស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និង សំណើសូចនាករតាមដានរួមគ្នាថ្មីសំរាប់វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣**

## ១. សេចក្តីផ្តើម

ក្រុមការងារបច្ចេកទេសចំរុះសំរាប់វិស័យព្រៃឈើនិងបរិស្ថាន(TWG-F&E) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៤ ដោយរាជរដ្ឋាភិបាលកម្ពុជា ។ លេខាធិការដ្ឋានរបស់ក្រុមការងារបច្ចេកទេសត្រូវបានរៀបចំនិងដំណើរការពេញលេញនៅក្នុងខែកក្កដា ២០០៦ ។

ក្រុមការងារ TWG-F&E គឺជាយន្តការមួយដើរតួនាទីជាវេទិកាសំរាប់សំរបសំរួលលើការងារជំនួយនិងការគាំទ្រដល់បណ្តាអ្នកពាក់ព័ន្ធក្នុងវិស័យព្រៃឈើនៅថ្នាក់កំរិតបច្ចេកទេសសំរាប់ជាជំនួយដល់ការសំរបសំរួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នៅក្នុងវិស័យព្រៃឈើ ។

ប្រធានក្រុមការងារ TWG-F&E គឺ ឯកឧត្តម ទី សុគន្ធ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ ។ ប្រធានសំរបសំរួលដៃគូអភិវឌ្ឍន៍ គឺតំណាងអង្គការ DANIDA ។

លេខាធិការដ្ឋាន TWG-F&E បានទទួលការគាំទ្រពីអង្គការ DANIDA តាមរយៈ Multi-Donor Livelihoods Facility (Danida-Dfid-NZAID) ។

ក្រុមការងារ TWG-F&E មានសមាជិកចំនួន២១នាក់ដែលមានតំណាងមកពីៈ

- ស្ថាប័នរាជរដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ក្រសួងដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងការពារជាតិ ក្រសួងពាណិជ្ជកម្ម ។
- ដៃគូអភិវឌ្ឍន៍ៈ អង្គការ Danida/Dfid; JICA; EC/EU; FAO; USAID; UNDP, AFD; WB
- អង្គការមិនមែនរដ្ឋាភិបាលៈ WCS; RECOFTC, PACT, NGO Forum
- វិស័យឯកជនៈ សមាគមឧស្សាហកម្មឈើកម្ពុជា (CTIA)

## ២. វឌ្ឍនភាពនៃការអនុវត្ត JMI នៃ CDCF លើកទី២

គោលបំណងនៃ JMI: ដើម្បីបញ្ឈប់ការបាត់បង់ធនធានព្រៃឈើ ដែលឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា និងយុទ្ធសាស្ត្រចតុកោណ និងដើម្បីគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព ដើម្បីកាត់បន្ថយភាពក្រីក្រ និងបំរែបំរួលអាកាសធាតុ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនក្របខ័ណ្ឌគតិយុត្តិដែលមានចែងក្នុងច្បាប់ព្រៃឈើ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ភូមិបាល ច្បាប់រ៉ែ និងពិសេស អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច នៅគ្រប់កំរិត ព្រមទាំងបញ្ចប់កម្មវិធីព្រៃឈើជាតិ និងការអភិវឌ្ឍន៍សហគមន៍ ។ សំរាប់ក្រុមការងារ TWG-F&E មាន JMI ចំនួន ៤ សំខាន់ៗៈ

២.១ អនុវត្តបណ្តាច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ដោយត្រូវរៀបចំសៀវភៅចុះបញ្ជីនិងផ្សព្វផ្សាយជាសាធារណៈអំពីដីសម្បទានសេដ្ឋកិច្ច សម្បទានរ៉ែ និងសម្បទានផ្សេងៗទៀតដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងក្រសួងបរិស្ថាន ។

- ក្រសួងកសិកម្ម បានផ្តល់ដីសម្បទានសេដ្ឋកិច្ចសរុបចំនួន ៩៩២.៨០០ ហ.ត ដល់ក្រុមហ៊ុនចំនួន ៨៧ ដោយបានចុះ

បញ្ជីក្នុង សៀវភៅ ។ ព័ត៌មានស្តីពីដីសម្បទានសេដ្ឋកិច្ចចំនួន ៧២ក្រុមហ៊ុនបានផ្សព្វផ្សាយក្នុងគេហទំព័រ www.elc.maff.gov.kh ក្រុមហ៊ុនផ្សេងៗទៀតនឹងដាក់ផ្សាយក្នុងគេហទំព័រឆាប់នេះ ។

- ក្រសួងឧស្សាហកម្ម បានផ្តល់អាជ្ញាប័ណ្ណរុករករ៉ែចំនួន១០០ ដល់៦៧ក្រុមហ៊ុន ហើយមានតែក្រុមហ៊ុនពីរ-បីប៉ុណ្ណោះកំពុងធ្វើការសិក្សា ។
- ក្រសួងបរិស្ថានបានផ្តល់ ដីវិនិយោគអភិវឌ្ឍន៍ ចំនួន៣៤៨.៦៥៦ហ.ត ។

ការផ្តល់ដីសម្បទានគឺជាបញ្ហាប្រឈមមួយដល់កិច្ចប្រឹងប្រែងថែរក្សាគំរបព្រៃឈើចំនួន៦០%នៃផ្ទៃដីប្រទេស ដូចមានចែងក្នុង NSDP និង CMDG ។

២.២ បោះព្រំប្រទល់ដែនព្រៃឈើឱ្យបានយ៉ាងតិច១.០០០ គ.ម និងកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបានយ៉ាងតិច២តំបន់ ទាំងនៅលើផែនទី ទាំងនៅមូលដ្ឋាន ។

- ក្នុងឆ្នាំ២០០៩ រដ្ឋបាលព្រៃឈើ និងអង្គការ NGOs កំណត់ព្រំប្រទល់ព្រៃឈើរដ្ឋបានប្រវែង 228,585គម
- ក្រសួងបរិស្ថានបានកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិទាំងនៅលើផែនទីនិងមូលដ្ឋានចំនួន២តំបន់( តំបន់ដែនជំរកសត្វព្រៃភ្នំសំកុសនិងគូលែន-ព្រហ្មទេព) ។

បញ្ហាប្រឈម គឺខ្វះធនធានហិរញ្ញវត្ថុ និងកិច្ចសហការពីអាជ្ញាធរមូលដ្ឋាននៅមានកំរិត ។

២.៣ អនុម័តសហគមន៍ព្រៃឈើ ១០០ និងសហគមន៍តំបន់ការពារ ១០ យ៉ាងតិចថែមទៀត ។

- ក្រសួងកសិកម្មបានអនុម័ត សហគមន៍ព្រៃឈើចំនួន៤កន្លែង ។
- ក្រសួងបរិស្ថានបានបង្កើតសហគមន៍តំបន់ការពារធម្មជាតិចំនួន១១កន្លែង ។

បញ្ហាប្រឈម គឺក្រសួងកសិកម្ម យឺតយ៉ាវក្នុងការពិនិត្យនិងសំរេចលើសំណើសុំបង្កើតសហគមន៍ព្រៃឈើ ។ សំណើសុំបង្កើតសហគមន៍ព្រៃឈើចំនួន១៧៥ កំពុងនៅរង់ចាំក្រសួងកសិកម្មពិនិត្យនិងសំរេច ។

២.៤ រៀបចំបញ្ចប់កម្មវិធីព្រៃឈើជាតិ នៅខែកញ្ញា ២០០៩ និងអនុវត្តនៅដំណាច់ឆ្នាំ២០០៩ ។

ការរៀបចំកម្មវិធីព្រៃឈើជាតិត្រូវបានចប់សព្វគ្រប់ក្នុងខែតុលា ២០០៩ ហើយបានដាក់ជូនក្រសួងកសិកម្មពិនិត្យនិងសំរេច ដើម្បីដាក់រាជរដ្ឋាភិបាលពិនិត្យនិងសំរេច ។ ទន្ទឹមនឹងការរង់ចាំការសំរេចរបស់ក្រសួងកសិកម្ម រដ្ឋបាលព្រៃឈើកំពុងតែរៀបចំផែនការកម្មវិធីព្រៃឈើជាតិសំរាប់ឆ្នាំ២០១០ និងផែនការសំរាប់៥ឆ្នាំ ។

## ៣. វឌ្ឍនភាពនៃការអនុវត្តសកម្មភាពអាទិភាពស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ

យោងតាមស្មារតីនៃរបៀបវារៈទីក្រុង Accra សំរាប់សកម្មភាព (Accra Agenda for Action) និងដើម្បីបង្កើនប្រសិទ្ធភាពជំនួយ រដ្ឋបាលព្រៃឈើបានកំណត់សកម្មភាពសំខាន់ចំនួន២ ហើយអនុម័តដោយកិច្ចប្រជុំលើកទី១៤នៃ GDCC ក្នុងខែមេសា ២០០៩ ។

៣.១ កសាងសមត្ថភាព រៀបចំផែនការ អនុវត្ត តាមដាន និងវាយតំលៃ ហើយពង្រឹងប្រព័ន្ធតាមដាននិងវាយតំលៃនៅរដ្ឋបាលព្រៃឈើ ។

ការអភិវឌ្ឍន៍ផែនការសំរាប់ឆ្នាំ២០១០តំរឹមតាមកម្មវិធីព្រៃឈើជាតិគឺជាលំហាត់មួយសំរាប់ការកសាងសមត្ថភាពក្នុងការរៀបចំផែនការ ។ រដ្ឋបាលព្រៃឈើបានបង្កើតការិយាល័យតាមដាននិងវាយតំលៃ ហើយបានរៀបចំសំណើសំរាប់ពង្រឹងប្រព័ន្ធតាមដាននិងវាយតំលៃ ដាក់ស្នើសុំការគាំទ្រពីអង្គការ DANIDA ។

៣.២ រៀបចំនិងអនុវត្តកម្មវិធីព្រៃឈើជាតិ

ការរៀបចំកម្មវិធីព្រៃឈើជាតិចប់សព្វគ្រប់ ហើយនៅរង់ចាំការអនុម័តពីក្រសួងកសិកម្មនិងរាជរដ្ឋាភិបាល។ រដ្ឋបាលព្រៃឈើកំពុងតែរៀបចំផែនការកម្មវិធីព្រៃឈើជាតិសំរាប់ឆ្នាំ២០១០និងផែនការ៥ឆ្នាំ ហើយសង្ឃឹមថានឹងរៀបចំហើយនៅក្នុងខែឧសភា។

## ៤. អនុសាសន៍

- ក្រសួងបរិស្ថានគួរចាត់តាំងតំណាងថ្មីដែលមានតួនាទីអាចធ្វើការសំរេចចិត្តបាន មានកិច្ចសហការល្អ ដើម្បីចូលរួមជាសមាជិកក្រុមការងារ TWG-F&E ហើយមានឆន្ទៈចូលរួមយ៉ាងសកម្ម និងចែករំលែកព័ត៌មានជាមួយសមាជិក TWG-F&E។
- គួរតែបញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ព្រៃឈើនិងតំបន់ការពារធម្មជាតិ។ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវតែអនុវត្តតាម ផែនការមេ ជាពិសេស ការវិនិយោគទុនដាំឈើ ដើម្បីជួយបង្កើនគំរបព្រៃឈើឡើងវិញ។
- ស្នើសុំឱ្យក្រសួងកសិកម្មពិនិត្យនិងអនុម័តឱ្យបានទាន់ពេលវេលាលើសំណើសុំបង្កើតសហគមន៍ព្រៃឈើ និងកម្មវិធីព្រៃឈើជាតិ។
- ផ្តល់ធនធានមនុស្សនិងថវិកាបន្ថែមដល់រដ្ឋបាលព្រៃឈើសំរាប់ការអនុវត្តកម្មវិធីព្រៃឈើជាតិ។ ស្នើសុំឱ្យមានកិច្ចសហការពេញលេញពីអាជ្ញាធរមូលដ្ឋាន។
- ស្នើសុំឱ្យដៃគូអភិវឌ្ឍន៍ អង្គការមិនរដ្ឋាភិបាលទាំងអស់ ទាំងជាតិនិងអន្តរជាតិដែលគាំទ្រដល់វិស័យព្រៃឈើ ត្រូវតែចែករំលែកព័ត៌មានជាមួយក្រុមការងារ TWG-F&E។

## ៥. សំណើ JMI ថ្មីសំរាប់ CDCF លើកទី៣

ផ្អែកតាម NSDP និងកម្មវិធីព្រៃឈើជាតិ ក្រុមការងារ TWG-F&E ស្នើសុំកំណត់ JMI ថ្មីសំរាប់ CDCF លើកទី៣។ សូចនាករទាំងនេះនឹងត្រូវអនុវត្តសំរាប់រយៈពេល១៨ខែ គឺរហូតដល់ដំណាច់ឆ្នាំ២០១១។

## លទ្ធផលរយៈពេលខ្លី

គំរបព្រៃឈើនៃផ្ទៃដីប្រទេសត្រូវបានថែរក្សាដោយបង្កើនបរិមាណនិងគុណភាពនៃព្រៃឈើតាមរយៈការគ្រប់គ្រងធនធានព្រៃឈើឱ្យកាន់តែប្រសើឡើង។ JMI សំខាន់ៗមានចំនួន៤គឺ:

- ដាំឈើឡើងវិញចំនួន ២៥.000ហ.ត លើដីរេចរឹល។
- បោះព្រំប្រទល់ដែនព្រៃឈើឱ្យបានចំនួន ៧៥0គ.ម និងបោះព្រំប្រទល់តំបន់ការពារធម្មជាតិចំនួន៤កន្លែង។
- អនុម័តសហគមន៍ព្រៃឈើឱ្យបានចំនួន១00សហគមន៍ និងសហគមន៍តំបន់ការពារធម្មជាតិចំនួន៧សហគមន៍។
- អនុម័តនិងអនុវត្ត ផែនទីផ្លូវ (ផែនការ) ស្តីពីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការអនុវត្តយន្តការ REDD។

ព័ត៌មានពិស្តារដូចមានតារាងជូនភ្ជាប់។

របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត JMI និងសំណើ JMI ថ្មីត្រូវបានពិភាក្សានិងអនុម័តដោយក្រុម TWG-F&E នៅក្នុងសម័យប្រជុំលើកទី២៥ នៅថ្ងៃទី៣ មីនា ២០១០។

| | |
|---|---|
| ហត្ថលេខា | ហត្ថលេខា |
| Jacob K. Jepsen<br>Lead Facilitator of TWG-F&E | H.E Ty Sokhun<br>Chairman of TWG-F&E |

## New JMI of TWG-F&E for the 3rd CDCF

<table>
<tr><th colspan="3">Results: outcome, output and indicators</th><th colspan="2">Activities: milestone actions</th><th colspan="4">Inputs: management, coordination and resourcing</th></tr>
<tr><th>immediate outcome</th><th>output</th><th>output indicator</th><th>Activity</th><th>Associated aid effectiveness actions</th><th>Coordinating institution</th><th>Implementing institution</th><th>Timeline</th><th>Funding and other inputs</th></tr>
<tr><td>1</td><td>2</td><td>3</td><td>4</td><td>5</td><td>6</td><td>7</td><td>8</td><td>9</td></tr>
<tr><td rowspan="4">គំរបព្រៃឈើនៃផ្ទៃដីប្រទេសត្រូវបានថែរក្សាដោយបង្កើនបរិមាណនិងគុណភាពព្រៃឈើតាមរយៈការគ្រងធនធានព្រៃឈើកាន់តែប្រសើឡើង។</td><td rowspan="4">ការអនុវត្តកម្មវិធីព្រៃឈើជាតិក្នុងការរៀបចំផែនការនិងការគ្រប់គ្រងវិស័យព្រៃឈើ កាន់តែប្រសើឡើង។</td><td rowspan="4">ជំរុញការអនុវត្តកម្មវិធីព្រៃឈើជាតិទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ យ៉ាងហោចណាស់៧៥% នៃមូលនិធិគាំទ្រសរុបដល់វិស័យព្រៃឈើត្រូវតំរឹមតាមក្របខណ្ឌកម្មវិធីព្រៃឈើជាតិ។</td><td>ការដាំព្រៃឡើងវិញលើដីរេចរឹលឱ្យបាន ២៥.000 ហ.ត</td><td rowspan="2">ពង្រឹងការរៀបចំផែនការប្រចាំឆ្នាំដើម្បីគាំទ្រដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។</td><td>រដ្ឋបាលព្រៃឈើ<br>ក្រសួងកសិកម្ម</td><td>រដ្ឋបាលព្រៃឈើ<br>ក្រុមហ៊ុនឯកជន</td><td rowspan="4">១៨ ខែ</td><td>រដ្ឋាភិបាល<br>ក្រុមហ៊ុនឯកជន</td></tr>
<tr><td>បោះព្រំប្រទល់ព្រៃឈើឱ្យបាន៧៥0គ.ម និង បោះព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបាន៤តំបន់។</td><td>រដ្ឋបាលព្រៃឈើ<br>ដៃគូអភិវឌ្ឍន៍<br>ក្រសួងកសិកម្ម<br>អាជ្ញាធរមូលដ្ឋាន</td><td>រដ្ឋបាលព្រៃឈើ<br>NGOs</td><td>រដ្ឋាភិបាល<br>ដៃគូអភិវឌ្ឍន៍<br>NGOs</td></tr>
<tr><td>អនុម័តសហគមន៍ព្រៃឈើឱ្យបាន១00 និងសហគមន៍តំបន់ការពារធម្មជាតិឱ្យបាន៧សហគមន៍។</td><td>អនុម័តផែនការរៀបចំតំបន់សហគមន៍ព្រៃឈើចំនួន២លានហ.ត នៅលើផែនទីដោយក្រសួងកសិកម្ម។</td><td>រដ្ឋបាលព្រៃឈើ<br>ដៃគូអភិវឌ្ឍន៍<br>ក្រសួងកសិកម្ម<br>ក្រសួងបរិស្ថាន<br>អាជ្ញាធរមូលដ្ឋាន</td><td>រដ្ឋបាលព្រៃឈើ<br>ក្រសួងកសិកម្ម<br>ក្រសួងបរិស្ថាន<br>NGOs</td><td>រដ្ឋាភិបាល<br>ដៃគូអភិវឌ្ឍន៍<br>NGOs</td></tr>
<tr><td>អនុម័តនិងអនុវត្តផែនទីផ្លូវ/ផែនការស្តីពីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការអនុវត្តយន្តការ REDD</td><td>រៀបចំនិតិវិធីច្បាប់ និងបទញ្ញត្តិសំរាប់ REDD</td><td>រដ្ឋបាលព្រៃឈើ<br>ដៃគូអភិវឌ្ឍន៍<br>ក្រសួងកសិកម្ម<br>ក្រសួងបរិស្ថាន<br>NGOs</td><td>រដ្ឋបាលព្រៃឈើ<br>ដៃគូអភិវឌ្ឍន៍<br>ក្រសួងបរិស្ថាន</td><td>រដ្ឋាភិបាល<br>ដៃគូអភិវឌ្ឍន៍<br>NGOs</td></tr>
</table>